# មហាវិទ្យាល័យស្ថាបត្យកម្ម

## ១. ស្ថានភាពទូទៅរបស់មហាវិទ្យាល័យ

*មហាវិទ្យាល័យស្ថាបត្យកម្ម និងនគរោបនីយវិទ្យាគឺជាអង្គភាពមួយចំណុះឲ្យសាកលវិទ្យាល័យ ភូមិន្ទវិចិត្រសិល្បៈ។មហាវិទ្យាល័យបណ្តុះបណ្តាលត្រឹមកម្រឹតបរិញ្ញាបត្រលើវិស័យស្ថាបត្យកម្ម។ ការសិក្សានៅក្នុងមហាវិទ្យាល័យនេះមានរយៈពេល៤ឆ្នាំ ពី (ឆ្នាំទី២ ដល់ឆ្នាំទី៥) បន្ទាប់ពីឆ្លងកាត់ការបណ្តុះបណ្តាលនៅថ្នាក់មូលដ្ឋាន១ឆ្នាំរួចមក។ មហាវិទ្យាល័យមានសាស្ត្រាចារ្យជំនាញជាតិ និង អន្តរជាតិជាច្រើនដែលកំពុងបម្រើការងារបណ្តុះបណ្តាលប្រកបដោយគុណភាព។ ក្រៅពីការសិក្សាទ្រឹស្តី និស្សិតត្រូវចុះកម្មសិក្សាអនុវត្តជាក់ស្តែង ទៅលើអ្វីដែលបានរៀនសូត្រនៅក្នុងថ្នាក់ទាំងតាមរយៈការ សិក្សាដែលរៀបចំដោយមហាវិទ្យាល័យ ទាំងតាមរយៈគ្រូទទួលបន្ទុកមុខវិជ្ជានិមួយៗ និង ទាំងតាមរយៈ ទំនាក់ទំនងជាឯកជនដែលនិស្សិតម្នាក់ៗមានជាមួយនឹងស្ថាប័នខាងក្រៅ ក្នុងបំណងផ្សារភ្ជាប់រវាង ចំណេះដឹង និងចំណេះធ្វើ ។ បន្ថែមពីលើនេះ មហាវិទ្យាល័យក៏បានអញ្ជើញវាគ្មិនសំខាន់ៗទាំង វាគ្មិនជាតិ និងអន្តរជាតិ មកធ្វើបទបង្ហាញជារឿយៗទៅលើប្រធានបទនានាចែកជូនដល់និស្សិត និង សាស្ត្រាចារ្យដើម្បីពង្រីកចំណេះដឹងបន្ថែម។ និស្សិតដែលមានការសិក្សាល្អ មហាវិទ្យាល័យបញ្ជូន ទៅចូលរួមវគ្គសិក្ខាសាលាអន្តរជាតិនានា ក៏ដូចជាការប្រកួតប្រជែងស្នាដៃស្ថាបត្យកម្ម ឬទស្សនៈកិច្ច សិក្សាជាដើម ។ ចាប់តាំងពីបើកទ្វារជាថ្មី នៅឆ្នាំ១៩៨៩ រហូតមកដល់បច្ចុប្បន្ននេះ មហា-វិទ្យាល័យ បានបង្កើតនូវធនធានមនុស្ស ដែលសព្វថ្ងៃកំពុងបំពេញនូវតួនាទីសំខាន់ៗ នៅក្នុងជួររដ្ឋាភិបាល អង្គការក្រៅរដ្ឋាភិបាលជាតិ និងអន្តរជាតិ ជាសហគ្រិន ជាអ្នកពិគ្រោះយោបល់ ជាអ្នកបម្រើការឲ្យក្រុម ហ៊ុនសហគ្រាសក្នុងស្រុកជាតិ និងអន្តរជាតិ រួមចំណែកបម្រើឲ្យតម្រូវការទីផ្សារការងារ និងក្នុងការស្តារ និងអភិវឌ្ឍន៍ប្រទេសជាតិឡើងវិញ ។*

## ២. ប្រវត្តមហាវិទ្យាល័យ

មហាវិទ្យាល័យស្ថាបត្យកម្ម និងនគរូបនីយវិទ្យា គឺជាគ្រឹះស្ថានសិក្សាមួយដែលបានបើកទ្វារសម្រាប់ការបណ្តុះបណ្តាលនៅឆ្នាំ ១៩៦៦ ទន្ទឹមគ្នានឹងការបើកបដិសន្ធិរបស់សាកលវិទ្យាល័យភូមិន្ទ វិចិត្រសិល្បៈដែរ ។ បន្ទាប់ពីការដួលរលំនៃរបបប៉ុលពត មហាវិទ្យាល័យស្ថាបត្យកម្ម និងនគរូបនីយ វិទ្យាបានបើកទ្វារជាថ្មីឡើងវិញនៅឆ្នាំ១៩៨៩ ។ ចាប់ពីឆ្នាំ១៩៨៩ មកដល់ឆ្នាំសិក្សា ២០១៣-២០១៤ នេះ យើងបណ្តុះបណ្តាលនិស្សិតបានចំនួន ១១៦៩នាក់ ក្នុងនោះមាននិស្សិតនារីចំនួន១១៣នាក់។ បច្ចុប្បន្ននិស្សិតមានចំនួន ៧៦២នាក់ ក្នុងនោះមាននិស្សិតនារីចំនួន ១៤៣នាក់ ។

## ៣. កម្មវិធីសិក្សាឆ្នាំនីមួយៗ របស់មហាវិទ្យាល័យស្ថាបត្យកម្ម និងនគរូបនីយវិទ្យា

កម្មវិធីសិក្សាឆ្នាំទី២ មាន ១១មុខវិជ្ជា៖

១. សិក្សាពេងជាងស្ថាបត្យកម្ម (មុខវិជ្ជាស្នូល)
២. គំនូរព្រាងស្ថាបត្យកម្ម (មុខវិជ្ជាតម្រូវការ)
៣. ក្បាច់ខ្មែរ (មុខវិជ្ជាតម្រូវការ)
៤. គំនូរពណ៌ (មុខវិជ្ជាតម្រូវការ)
៥. ស្តាទិចស្ថាបត្យកម្ម (មុខវិជ្ជាតម្រូវការ)
៦. ប្រព័ន្ធពត៌មានភូមិសាស្ត្រ (មុខវិជ្ជាតម្រូវការ)
៧. ប្រវត្តិសិល្បៈខ្មែរ (មុខវិជ្ជាតម្រូវការ)
៨. ប្រវត្តិស្ថាបត្យកម្មខ្មែរ (មុខវិជ្ជាតម្រូវការ)
៩. ធរណីមាត្រអត្ថាធិប្បាយ (មុខវិជ្ជាតម្រូវការ)
១០. គណិតវិទ្យា (មុខវិជ្ជាជ្រើសរើស)
១១. ទំរង់សំណង់ប្រពៃណីខ្មែរ (មុខវិជ្ជាជ្រើសរើស)

កម្មវិធីសិក្សាឆ្នាំទី៣ មាន ០៨មុខវិជ្ជា៖

១. សិក្សាពេងជាងស្ថាបត្យកម្ម (មុខវិជ្ជាស្នូល)

២. រចនាដោយកំព្យូទ័រ (មុខវិជ្ជាតម្រូវការ)

៣. សំណង់ចម្ងាក់ស្ថាបត្យកម្ម (មុខវិជ្ជាតម្រូវការ)

៤. សិល្បៈខ្មែរនិងសិល្បៈឆ្នៃប្រឌិត (មុខវិជ្ជាតម្រូវការ)

៥. គ្រឿងបង្គុំបេតុង (មុខវិជ្ជាតម្រូវការ)

៦. គ្រឿងបង្គុំដែក (មុខវិជ្ជាតម្រូវការ)

៧. ស្ថាបត្យកម្មដោយនិរន្តរភាព (មុខវិជ្ជាតម្រូវការ)

៨. ប្រវត្តិទូទៅនៃស្ថាបត្យកម្ម (មុខវិជ្ជាតម្រូវការ)

កម្មវិធីសិក្សាឆ្នាំទី៤មាន ០៩មុខវិជ្ជាៈ

១. សិក្សាពេងជាងស្ថាបត្យកម្ម (មុខវិជ្ជាស្នូល)

២. ផែនការទីក្រុងនិងការកសាងបរិស្ថាន (មុខវិជ្ជាស្នូល)

៣. គម្រោងផែនការទីក្រុង (មុខវិជ្ជាស្នូល)

៤. បច្ចេកទេសសំណង់ (មុខវិជ្ជាតម្រូវការ)

៥. ភាពធន់របស់សម្ភារៈ (មុខវិជ្ជាតម្រូវការ)

៦. គ្រឿងបង្គុំស្ថាបត្យកម្ម (មុខវិជ្ជាតម្រូវការ)

៧. អភិរក្សស្ថាបត្យកម្ម (មុខវិជ្ជាតម្រូវការ)

៨. គ្រប់គ្រង (មុខវិជ្ជាតម្រូវការ)

៩. ការសិក្សា(បរិស្ថាននិងប្រព័ន្ធអគារ (មុខវិជ្ជាតម្រូវការ)

មុខវិជ្ជា ៖ ០៦ មាន៥ កម្មវិធីសិក្សាឆ្នាំទី៥

១. សិក្សាពេងជាងស្ថាបត្យកម្ម (មុខវិជ្ជាស្នូល)

២. គម្រោងផែនការទីក្រុង (មុខវិជ្ជាស្នូល)

៣. សារណា (មុខវិជ្ជាស្នូល)

៤. បទពិសោធន៍ការងារ (មុខវិជ្ជាស្នូល)

៥. វិធីសាស្ត្រសរសេរនិក្ខេបបទ (មុខវិជ្ជាតម្រូវការ)

៦. គំនិតពិចារណានិងការបង្កើតថ្មី (មុខវិជ្ជាតម្រូវការ)

## ៣. អនុស្សារណៈស្តីពីការយោគយល់រវាងសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ (សម្រាប់មហាវិទ្យាល័យស្ថាបត្យកម្ម និងនគរូបនីយវិទ្យា) និងដៃគូនានា

| ល.រ | ឈ្មោះសាកលវិទ្យាល័យ ឬដៃគូ | ប្រទេស | តាំងពី/ឆ្នាំ |
|---|---|---|---|
| ១ | សាកលវិទ្យាល័យ ជូឡាឡុងកន | ថៃ | ២០០១ |
| ២ | សាកលវិទ្យាល័យ សិល្បៈកន | ថៃ | ២០០៤ |
| ៣ | សាកលវិទ្យាល័យ ឈៀងម៉ៃ | ថៃ | ២០០៤ |
| ៤ | សាកលវិទ្យាល័យ ណាហ្សាន់ | ជប៉ុន | ២០០៤ |
| ៥ | សាកលវិទ្យាល័យ សូហ្វីយ៉ា | ជប៉ុន | ២០០៤ |
| ៦ | សេវាអភិវឌ្ឍន៍អាល្លឺម៉ង់ | អាល្លឺម៉ង់ | ២០០៥ |
| ៧ | រាជបណ្ឌិតសភាកម្ពុជា | កម្ពុជា | ២០០៥ |
| ៨ | ក្រុមរដ្ឋាភិបាលជប៉ុនដើម្បីថែរក្សាអង្គរ | ជប៉ុន | ២០០៥ |
| ៩ | សាលាជាតិជាន់ខ្ពស់ស្ថាបត្យកម្មប៉ារីស ប៉ែលវីល | បារាំង | ២០១៤ |
| | | | |